**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមុខងារសាធារណៈ**

# លិខិតជូនពរ

## សូមគោរពជូន
## សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សម្តេចក្រឡាហោម ជាទីគោរពដ៏ខ្ពង់ខ្ពស់**

ក្នុងឱកាសចម្រើនជន្មាយុគម្រប់៧០ឆ្នាំ ឈានចូល៧១ឆ្នាំ របស់ **សម្តេចក្រឡាហោម** នៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០២១នេះ យើងខ្ញុំជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួងមុខងារសាធារណៈ មានសេចក្តីសប្បាយរីករាយឥតឧបមា សូមចូលរួមអបអរសាទរ និងជូនពរ **សម្តេចក្រឡាហោម** សូមសម្រេចប្រកបដោយសុខភាពល្អបរិបូរណ៍ កាយពលមាំមួន បញ្ញាញាណវាងវៃ និងជន្មាយុយឺនយូរ។

ឆ្លៀតក្នុងឱកាសដ៏វិសេសវិសាលនេះ យើងខ្ញុំទាំងអស់សូមសម្តែងនូវគារវកិច្ចគោរពដឹងគុណដ៏ស្មោះចំពោះទឹកចិត្តដ៏ថ្លៃថ្លា និងសកម្មភាពដ៏ឧត្តុង្គឧត្តមរបស់ **សម្តេចក្រឡាហោម** នៅក្នុងបេសកកម្មដឹកនាំក្រសួងមហាផ្ទៃ ដើម្បីបន្តថែរក្សាការពារបានសុខសន្តិភាព ស្ថិរភាព សន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ ការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ការពង្រឹងលទ្ធិប្រជាធិបតេយ្យនិងនីតិរដ្ឋ ការគោរពសិទ្ធិមនុស្ស ការប្រយុទ្ធប្រឆាំងគ្រឿងញៀន ការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ សំដៅចូលរួមជាឧត្តមប្រយោជន៍សាធារណៈដ៏ធំធេង សម្រាប់សង្គមជាតិ និងប្រជាជននៅទូទាំងប្រទេស។

ជាថ្មីម្តងទៀត យើងខ្ញុំទាំងអស់គ្នាសូមអនុញ្ញាតគោរពជូនពរ **សម្តេចក្រឡាហោម និង លោកជំទាវ ព្រមទាំង បុត្រា បុត្រី ចៅប្រុស ចៅស្រី** ជាទីស្រលាញ់របស់សម្តេច សូមបានប្រកបដោយពុទ្ធពរទាំង៤ ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** មេត្តាទទួលនូវសេចក្តីគោរពដ៏ជ្រាលជ្រៅ និងខ្ពង់ខ្ពស់បំផុតពីយើងខ្ញុំ។

ថ្ងៃ ពុធ ១៥រោច ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មករា ឆ្នាំ២០២១
**រដ្ឋមន្ត្រី**

ព្រំ-សុខា